# អង្គការខារ៉ាមកម្ពុជា

Coordination of Action Research on AIDS and Mobility (CARAM Cambodia)

# ស្ថានភាពពលករចំណាកស្រុកកម្ពុជា ដែលត្រូវ ចាប់បញ្ជូន ដោយរបបយោធាថៃ

## នៅច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី ០៦ — ២៨ ខែ មិថុនា ឆ្នាំ ២០១៤




**រៀបចំដោយៈ**

**ឧបត្ថម្ភដោយៈ**

## មាតិកា


១. សាវតា និងបរិបទ .................................... ១

២. គោលបំណង .................................... ២

៣. វិធីសាស្ត្រ .................................... ២

៤. លទ្ធផលរកឃើញ .................................... ២-៤

៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ .................................... ៤-៧

ឯកសារយោង .................................... ៨

## ១. សាវតា និងបរិបទ

បន្ទាប់ពីវិបត្តិនយោបាយអស់រយៈពេលជាង៦ខែ កាលពីថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៤ កងទ័ពខេមរៈភូមិន្ទថៃ ដែលដឹកនាំដោយ ឧត្តមសេនីយ៍ ប្រាយុទ្ធ ចាន់អូចា មេបញ្ជាការកងទ័ពខេមរភូមិន្ទថៃ បានធ្វើរដ្ឋប្រហារទំលាក់រដ្ឋាភិបាលចាំផ្ទះ ហើយបានបង្កើតរបបយោធាមួយហៅថា **"ក្រុមប្រឹក្សាជាតិ ដើម្បីសន្តិភាព និង សណ្តាប់ធ្នាប់"** ដើម្បីគ្រប់គ្រងប្រទេសថៃ[១] ។

បន្ទាប់ពីរដ្ឋប្រហារនៅក្នុងប្រទេសថៃ យើងសង្កេតឃើញថា ពលករបរទេសមិនមានឯកសារ ដែលមកពីប្រទេសឡាវ ភូមា និងកម្ពុជា ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ត្រូវបានចាប់ខ្លួន ឃុំខ្លួន និងបញ្ជូនត្រឡប់មកប្រទេសកំណើតរបស់ខ្លួនវិញ ជាពិសេសពលករចំណាកស្រុកកម្ពុជាប្រមាណជាង ២៥០ ០០០[២] (ម្ភៃប្រាំម៉ឺននាក់) ត្រូវបានចាប់បញ្ជូន យ៉ាងតក់ក្រហល់ និងគំហុក កាលពីថ្ងៃទី ០៦-២៨ ខែ មិថុនា ឆ្នាំ ២០១៤ ដោយរបបយោធាថៃ ដែលបានធ្វើអោយសហគមន៍ជាតិ និងអន្តរជាតិ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង និងបានថ្កោលទោសរបបយោធាថៃបច្ចុប្បន្នថា បានកំពុងរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ និងអមនុស្សធម៌មិនជាទីបំផុត ជាពិសេសសិទ្ធិពលករចំណាកស្រុកកម្ពុជា[៣] ដោយធ្វើឱ្យអ្នកវិភាគនយោបាយ ក្នុងស្រុកមួយចំនួនលើកឡើងថា ការចាប់បញ្ជូនពលករកម្ពុជាយ៉ាងតក់ក្រហល់ និងគំហុកដូច្នេះ ដោយសារតែហេតុផលនយោបាយ ទី១: របបយោធាថៃកំពុងមានការព្រួយបារម្ភណ៍ អំពីរដ្ឋាភិបាលស្រមោលរបស់អតីតនាយករដ្ឋមន្ត្រី ថាក់ ស៊ិន អាចបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា ដោយសារតែមានទំនាក់ទំនងជិតស្និទជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ទី២: ដើម្បីរៀបចំរបបយោធាថៃឱ្យក្លាយទៅជារដ្ឋាភិបាលស្របច្បាប់មួយនៅពេលឆាប់ៗខាងមុខ តាមរយៈការបោះឆ្នោតជាតិមួយ ដើម្បីបង្វែរការចាប់អារម្មណ៍របស់សហគមន៍អន្តរជាតិ កុំអោយថ្កោលទោសទៅលើរបបយោធាថៃ និង ទី៣: ដោយមានការព្រួយបារម្ភណ៍ថា ពលករចំណាកស្រុកកម្ពុជា អាចនឹងជាប់ពាក់ព័ន្ធជាមួយគណបក្សភើថៃ របស់អតីតនាយករដ្ឋមន្ត្រី យីង ឡាក់ និងអាចគាំទ្របាតុករអាវក្រហម ដែលមានភក្តីភាពជាមួយអតីតនាយករដ្ឋមន្ត្រី ថាក់ស៊ិន[៤] ។

---

[1] (2014 Thai Coup detat )
[2] ((MoLVT), 2014)
[3] ((CHRAC), 2014)
[4] ((RFA), 2014)

## ២. គោលបំណង

ការត្រួតពិនិត្យស្ថានភាពពលករចំណាកស្រុកកម្ពុជា ដែលត្រូវចាប់បញ្ជូនដោយរបបយោធាថៃ យ៉ាងតក់ក្រហល់ និងគំហុក តាមច្រកទ្វារព្រំដែនអន្តរជាតិ ប៉ោយប៉ែត ត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បី **ទី១) ស្វែងយល់ពីបញ្ហាប្រឈមនានា របស់ពលករកម្ពុជា ក្នុងកំឡុងពេលនៃការចាប់ខ្លួន ឃុំខ្លួន និងការបញ្ជូនខ្លួនត្រឡប់មកប្រទេសកំណើតវិញ** និង **ទី២) កំណត់យុទ្ធសាស្ត្រឆ្លើយតបចំពោះបញ្ហាប្រឈមរបស់ពលករចំណាកស្រុក ទាក់ទិននឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ និងការអភិវឌ្ឍន៍** ។

## ៣. វិធីសាស្ត្រ

ក្រុមការងារអង្គការខារ៉ាមកម្ពុជា បានធ្វើការសំភាសន៍ពលករកម្ពុជា ដោយផ្ទាល់មួយទល់មួយ និង សំភាសន៍ជាក្រុម ដោយមានពលករសរុបទាំងអស់ចំនួន ១១១ នាក់ ព្រមទាំងចុះទៅជួបសំភាសន៍ដោយផ្ទាល់ នៅតាមសហគមន៍ នៅពេលដែលពួកគេបានមកដល់ផ្ទះសំបែង ព្រមទាំងដកស្រង់ឯកសារយោង ពីប្រភពសារពត៌មានជាតិ និងអន្តរជាតិ និងគេហទំព័រផ្សេងៗ ។

## ៤. លទ្ធផលរកឃើញ

យោងទៅលើការសំភាសន៍ពលករចំណាកស្រុកកម្ពុជា ដែលត្រូវបានចាប់បញ្ជូនយ៉ាងតក់ក្រហល់ និងគំហុក ព្រមទាំងការចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយពលករដែលបានវិលត្រឡប់មកវិញដោយការចាប់បញ្ជូន និងជួបជាមួយក្រុមគ្រួសាររបស់គេ និងសេចក្តីរាយការណ៍ផ្សេងៗតាមសារពត៌មានជាតិ និងអន្តរជាតិ អង្គការខារ៉ាមកម្ពុជា បានរកឃើញបញ្ហាប្រឈមនានា របស់ពលករចំណាកស្រុកកម្ពុជា ដែលត្រូវបានចាប់បញ្ជូនខ្លួនដោយរបបយោធាថៃ ដូចតទៅ :

- ពលករកម្ពុជា១៣នាក់ ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ដោយអាជ្ញាធរថៃ ពីបទក្លែងត្រាទៅលើប័ណ្ណអនុញ្ញាតការងារ ដោយសារតែការសំរបសំរួលរបស់មេខ្យល់ ក្នុងការធ្វើប័ណ្ណអនុញ្ញាតការងារ និងឯកសារគតិយុត្តិផ្សេងៗ។

- ដោយសារតែមិនមាននីតិវិធីក្នុងការចាប់បញ្ជូនឱ្យបានច្បាស់លាស់ និងជូនដំណឹងជាមុនដល់ភាគីកម្ពុជា ពលករកម្ពុជារាប់សិបម៉ឺននាក់ ត្រូវបានចាប់បញ្ជូនដោយតក់ក្រហល និងគំហុក ដោយដឹកតាមរថយន្តទ្រុង ដែលមានផ្ទុកមនុស្សណែនតាន់តាប់ ប្រៀបដូចជាឡានដឹកទំនិញ និងសត្វ ។ លើសពីនោះទៀត របបយោធាថៃបានប្រើប្រាស់រថយន្តបែនដឹកដី ដោយចាក់ទំលាក់ពលករនៅច្រកទ្វារ អន្តរជាតិ ប៉ោយប៉ែត ដូចសត្វធាតុ ដែលបង្ហាញឱ្យឃើញនូវ ការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ និងអមនុស្សធម៌ ជាពិសេសសិទ្ធិពលករចំណាកស្រុក ។
- ពលករកម្ពុជាដែលត្រូវបានចាប់បញ្ជូនខ្លួនមួយចំនួន បានបាត់សំភារៈ និងឥវ៉ាន់របស់គាត់ ដោយសារតែមានការដឹកមនុស្ស និងឥវ៉ាន់ដាច់ដោយឡែកពីគ្នា ព្រមទាំងការចាប់បញ្ជូនមានចំនួនច្រើនលើសលប់ ។ លើសពីនោះទៅទៀត ពលករខ្លះ ចាញ់បោកមេខ្យល់នៅប្រទេសថៃ ដោយម្នាក់ៗត្រូវចំណាយប្រមាណ ២០០០បាត ជាថ្នូរនឹងការដឹកជញ្ជូនតាមរថយន្តឈ្នួលមកកាន់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ។
- ដោយសារតែមានបទបញ្ជា ដែលដាក់ចេញដោយរបបយោធាថៃ ដោយមិនអនុញ្ញាតឱ្យជួលពលករបរទេសខុសច្បាប់ និងដាក់ពិន័យធ្ងន់ធ្ងរចំពោះនិយោជកថៃទាំងឡាយណាដែលហ៊ានជួលពលករខុសច្បាប់ បានធ្វើអោយនិយោជកមួយចំនួនមានការព្រួយបារម្ភណ៍ ហើយប្រកាសឱ្យពលករចាកចេញ ដោយមិនបានបើកប្រាក់ឈ្នួលឱ្យ ហើយពលករខ្លះទៀត ទទួលបានប្រាក់ឈ្នួលតែពាក់កណ្តាលប៉ុណ្ណោះ ។ ទន្ទឹមនឹងនោះដែរ អាជ្ញាធរថៃ បានជំរិតយកលុយពីពលករខ្មែរក្នុងម្នាក់ៗចន្លោះពី ២០០ ទៅ ៦០០ បាត ជាថ្នូរនឹងការអនុញ្ញាតឱ្យវិលត្រឡប់មកប្រទេសកម្ពុជាវិញ បើពុំនោះសោតទេ អាចនឹងប្រឈមមុខការចាប់ខ្លួន និងការឃុំខ្លួន នៅក្នុងប្រទេសថៃ ក្រោមហេតុផលនៃការអនុវត្តន៏ច្បាប់អន្តោប្រវេសន៍ ។
- ពលករកម្ពុជាមួយចំនួនបានប្រឈមមុខ នឹងការដាច់បាយអស់រយៈពេល មួយថ្ងៃទៅពីរ (១-២) ថ្ងៃ ដោយសារការធ្វើដំណើរវិលត្រឡប់មកវិញ មានរយៈចំងាយឆ្ងាយ និងការជំរិតយកលុយតាមផ្លូវ ។
- ដោយសារមានការភ័យខ្លាចពីការចាប់ខ្លួន ការឃុំខ្លួន ដោយរបបយោធាថៃ បានធ្វើឱ្យពលករភាគច្រើនសំរេចចិត្តវិលត្រឡប់មកប្រទេសកម្ពុជាវិញដោយខ្លួនឯង តាមរយៈការចាត់ចែង របស់មេខ្យល់

ក្នុងការដឹកជញ្ជូនតាមរថយន្តឈ្នួល/ឯកជន ដែលបណ្តាលឱ្យពលករខ្លះ រងរបួសធ្ងន់ធ្ងរ និងស្លាប់បាត់បង់ជីវិត ដោយសារគ្រោះថ្នាក់ចរាចរណ៍ ។

- ជាការកត់សំគាល់ ពលករកម្ពុជាមួយចំនួន បានដួលសន្លប់ ប្រមាណ ពី៣ ទៅ៤ នាក់ ក្នុងមួយថ្ងៃៗ ដោយសារការដឹកជញ្ជូនមានលក្ខណៈណែនតាន់តាប់ ចំងាយឆ្ងាយ ច្រើនលើសលប់ និងការដាច់បាយ ។
- ដោយសារតែការដឹកជញ្ជូនពលករមានលក្ខណៈច្រើនគំហុក និងតក់ក្រហល់ ហេតុដូច្នេះហើយ ធ្វើអោយពលករត្រូវរង់ចាំរយៈពេលជាច្រើនម៉ោង ហើយពលករខ្លះ ត្រូវរង់ចាំអស់រយៈពេលរហូតទៅដល់មួយថ្ងៃ ដើម្បីអាចបានជិះរថយន្តធ្វើដំណើរត្រឡប់ទៅស្រុកកំណើតវិញ។ ដោយសារកត្តាទាំងអស់នេះហើយ ទើបបណ្តាលអោយខ្វះបង្គន់អនាម័យសំរាប់ប្រើប្រាស់ និងរថយន្តគ្រប់គ្រាន់ សម្រាប់ដឹកជញ្ជូនពលករត្រឡប់ទៅស្រុកកំណើតវិញ។
- ពលករកម្ពុជាភាគច្រើន មិនបានទទួលព័ត៌មានពីលេខទូរស័ព្ទទាន់ហេតុការណ៍ ដែលប្រកាសដោយស្ថានទូតកម្ពុជាប្រចាំនៅព្រះរាជាណាចក្រថៃទេ ទាក់ទិនទៅនឹងជំនួយសង្គ្រោះបន្ទាន់ បន្ទាប់ពីរដ្ឋប្រហារយោធា នៅក្នុងប្រទេសថៃ និងបម្រាបគោចរ ដែលដាក់ចេញដោយរបបសឹកយោធាថៃ។
- ក្នុងកំឡុងពេលនៃការចាប់បញ្ជូនពលករយ៉ាងតក់ក្រហល់ និងគំហុកនេះ មានជនឱកាសនិយមមួយចំនួនបានឆ្លៀតឱកាសកេងចំណេញពលករពីអត្រានៃការប្តូរប្រាក់ និងឆ្លៀតតំឡើងថ្លៃឈ្នួលរថយន្ត និងទំនិញផ្សេងៗ ដែលអាចធ្វើទៅបាន។

## ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ទោះបីជាពលករចំណាកស្រុកកម្ពុជា ត្រូវបានចាប់បញ្ជូនយ៉ាងគំហុក និងតក់ក្រហល់ ដោយរបបសឹកយោធាថៃ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារព្រំដែនផ្សេងៗទៀត ដោយមិនបានជូនដំណឹងផ្លូវការជាមុន មករដ្ឋាភិបាលកម្ពុជាក៏ដោយ ជាការកត់សំគាល់ យើងសង្កេតឃើញថា រដ្ឋាភិបាលកម្ពុជាអាចចាត់វិធានការណ៍បានទាន់ពេលវេលា និងឆ្លើយតបភ្លាមៗ ចំពោះបញ្ហាប្រឈម និងតំរូវការជាបន្ទាន់ ដែលពលករកម្ពុជាកំពុងជួបប្រទះ ក្នុងកំឡុងពេលនៃការចាប់បញ្ជូនយ៉ាងតក់ក្រហល់នេះ ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធ ជាមួយអង្គការជាតិ

និងអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍នានា ។ ទោះបីយ៉ាងណាក៏ដោយ ការចាប់បញ្ជូនពលករកម្ពុជាយ៉ាងគំហុក និងតក់ក្រហល់បែបនេះ វានឹងបន្ថែមបន្ទុកមួយក៏រិតទៀត ចំពោះរាជរដ្ឋាភិបាលកម្ពុជា នៅពេលដែលទីផ្សារការងារ បង្កើតឡើង មិនមានតុល្យភាពនឹងកំលាំងការងារដែលចេញក្នុងមួយឆ្នាំៗ ដែលជាហេតុធ្វើឱ្យពលករចំណាកស្រុក កម្ពុជាដែលត្រូវបានចាប់បញ្ជូនមក អាចប្រឈមមុខនឹងភាពអត់ការងារធ្វើ និងទទួលរងផលប៉ះពាល់ផ្សេងៗទៀត ដែលអាចជំរុញឱ្យពួកគាត់សំរេចចិត្តធ្វើចំណាកស្រុក ដោយប្រថុយប្រថាន/មិនស្របច្បាប់សាជាថ្មី ដែលពួកគាត់ អាចប្រឈមមុខនឹង ការកេងប្រវ័ញ្ចកំលាំងការងារ ការរំលោភសិទ្ធិមនុស្ស ការរំលោភបំពានផ្សេងៗ និងការជួញដូរមនុស្សសាជាថ្មី ។ ល។ ដោយមើលឃើញពីបញ្ហា និងផលប៉ះពាល់នានា ដែលពលករកម្ពុជា កំពុងប្រឈមមុខ ហេតុដូច្នេះហើយ អង្គការខារ៉ាមកម្ពុជា ដែលជាអង្គការមិនមែនរដ្ឋាភិបាល ដែលបានឃ្លាំមើល ស្ថានភាពនៃការចាប់បញ្ជូនពលករចំណាកស្រុកកម្ពុជា និងបានចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការ ឆ្លើយតបចំពោះបញ្ហា និងតំរូវការបន្ទាន់ ក្នុងកំឡុងពេលនៃការចាប់បញ្ជូនយ៉ាងគំហុក និងតក់ក្រហល់កាលពីថ្ងៃទី ០៦-២៨ មិថុនា ឆ្នាំ ២០១៤ និងជាអង្គការដែលធ្វើការ ដើម្បីការពារ និងលើកកំពស់សិទ្ធិពលករចំណាកស្រុក សូមអំពាវនាវ និង ស្នើដល់របបសឹកយោធាថៃ ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងភាគីពាក់ព័ន្ធនានាដូចតទៅ ៖

## ១. របបសឹកយោធាថៃ

- ការចាប់បញ្ជូនពលករកម្ពុជាយ៉ាងគំហុក និងតក់ក្រហល់ដូច្នេះ គួរតែមានការជូនដំណឹងជាលាយ លក្ខអក្សរ ឬពិភាក្សាជាមុន ជាមួយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈស្ថានកុងស៊ុល ឬស្ថានទូតកម្ពុជា ប្រចាំនៅព្រះរាជាណាចក្រថៃឡង់ ដោយមាននីតិវិធី ឬយន្តការច្បាស់លាស់ ក្នុងការចាប់បញ្ជូនខ្លួន ហើយធានាឱ្យមានការគោរពសិទ្ធិមនុស្សជាមូលដ្ឋាន និងសេចក្តីថ្លៃថ្នូរជាមនុស្សជាតិ ដូចដែលមានចែង នៅក្នុងសេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងសេចក្តីប្រកាសអាស៊ាន ស្តីពីការពារនិងលើកកំពស់សិទ្ធិពលករចំណាកស្រុក និងបទដ្ឋានលិខិតុបករណ៍អង្គការពលកម្មអន្តរជាតិ។
- របបសឹកយោធាថៃ គួរចាត់វិធានការណ៍តាមផ្លូវច្បាប់ និងស៊ើបអង្កេតទាក់ទិនទៅនឹងគ្រោះថ្នាក់ ចរាចរណ៍ ឬការបាញ់សម្លាប់ពលករកម្ពុជា ហើយផ្តន្ទាទោសជនប្រព្រឹត្តបទល្មើសទៅតាមផ្លូវច្បាប់ និង ផ្តល់សំណងជូនដល់ពលករ ឬក្រុមគ្រួសាររបស់គាត់។

## ២. រាជរដ្ឋាភិបាលកម្ពុជា

- រាជរដ្ឋាភិបាលកម្ពុជាគួរធ្វើការសិក្សាប៉ាន់ប្រមាណពីបញ្ហាប្រឈម តម្រូវការ និង កាលានុវត្តភាព របស់ពលករកម្ពុជាដែលត្រូវបានចាប់បញ្ជូនដោយរបបសឹកយោធាថៃ ហើយរៀបចំផែនការយុទ្ធសាស្ត្រ ដើម្បីឆ្លើយតបក្នុងរយៈពេលខ្លី មធ្យម និងវែង ក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារ និងការអភិវឌ្ឍន៍។
- ផ្អែកតាមបទពិសោធន៍នៃការចាប់បញ្ជូនយ៉ាងតក់ក្រហល់ និងគំហុកនេះ រាជរដ្ឋាភិបាលកម្ពុជាគួរតែរៀបចំអោយមានផែនការត្រៀមសង្គ្រោះបន្ទាន់ ក្នុងករណីមានព្រឹត្តិការណ៍អ្វីមួយកើតឡើងបន្ទាន់ចំពោះពលករចំណាកស្រុក ដែលអាចឆ្លើយតបបានទាន់ពេលវេលា ចំពោះបញ្ហាប្រឈម និងតម្រូវការបន្ទាន់របស់ពលករដូចជាៈ ការផ្តល់ស្បៀងអាហារបន្ទាន់ ការផ្តល់ជំរកបន្ទាន់ ការដឹកជញ្ជូន ការគាំទ្រផ្នែកវេជ្ជសាស្ត្រ និងការបញ្ជូនទៅរកសេវាគាំពារសុខភាព និងផ្លូវចិត្ត។
- រាជរដ្ឋាភិបាលគួរបង្កើតច្រកចេញចូលតែមួយនៅតាមបណ្តាខេត្តជាប់ព្រំដែនជាមួយប្រទេសថៃ ដោយផ្តល់ព័ត៌មានស្តីពីសុវត្ថិភាពចំណាកស្រុក ការបំពេញបែបបទធ្វើចំណាកស្រុកដោយស្របច្បាប់ និងកាត់បន្ថយតំលៃនៃការធ្វើចំណាកស្រុក និងប្រព័ន្ធការិយាធិបតេយ្យ ដើម្បីអោយពលករងាកត្រលប់មកធ្វើចំណាកស្រុកដោយស្របច្បាប់វិញ។
- រាជរដ្ឋាភិបាលគួររៀបចំកិច្ចពិភាក្សាពិគ្រោះយោបល់ ស្តីពីឱកាសការងារជាមួយសហគ្រាសខ្នាតតូច និងមធ្យម វិស័យវាយនភ័ណ្ឌ វិស័យទេសចរណ៍ និងសេវាកម្មផ្សេងៗទៀត ដើម្បីផ្តល់ការងារជូនពលករ។
- រាជរដ្ឋាភិបាលកម្ពុជាគួរពង្រីកការិយាល័យធ្វើលិខិតឆ្លងដែន នៅតាមបណ្តាខេត្តដែលមានពលករធ្វើចំណាកស្រុកច្រើន ដើម្បីសម្រួល សោហុយក្នុងការធ្វើដំណើរ និងការចំណាយផ្សេងៗរបស់ពលករ និងក្រុមគ្រួសាររបស់គេ។
- រាជរដ្ឋាភិបាលកម្ពុជាគួរបង្កើតអោយមានសេនានុព័ន្ធការងារ នៅតាមបណ្តាប្រទេសដែលមានពលករចំណាកស្រុកច្រើន ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងបញ្ហាប្រឈមបានទាន់ពេលវេលា និងមានប្រសិទ្ធិភាព។

- រាជរដ្ឋាភិបាលកម្ពុជាគួរចរចាជាមួយភាគីថៃ និងបណ្តាប្រទេសផ្សេងៗទៀតដែលមានពលករកម្ពុជាទៅធ្វើការងារ ក្នុងការបង្កើតកិច្ចព្រមព្រៀងទ្វេភាគី ស្តីពីការគ្រប់គ្រង និងការបញ្ជូនពលករទៅធ្វើការងារនៅបរទេស ។
- រាជរដ្ឋាភិបាលកម្ពុជាគួរពង្រឹងការប្រមូលពន្ធចំពោះដីដែលទុកចោលទំនេរ និងពិនិត្យមើលដោយសើរើឡើងវិញ ចំពោះដីសម្បទានសេដ្ឋកិច្ចដែលផ្តល់អោយក្រុមហ៊ុន និងបែងចែកដីសម្បទានសង្គមកិច្ចដល់ពលករ ឬប្រជាពលករដ្ឋណាដែលក្រីក្រពិតប្រាកដមែន ដើម្បីបង្កបង្កើនផលមុខរបរកសិកម្មរបស់គាត់ ។
- រាជរដ្ឋាភិបាលកម្ពុជាគួរជម្រុញអោយមានកសិឧស្សាហកម្មបន្ថែមទៀត តាមរយៈការពង្រីកប្រព័ន្ធធារាសាស្ត្រនៅតាមបណ្តាខេត្តផ្សេងៗ ដោយផ្តល់បច្ចេកទេសកសិកម្ម និង គ្រាប់ពូជដែលមានគុណភាពខ្ពស់ដល់កសិករ ព្រមទាំងបច្ចេកទេសក្នុងការកែច្នៃ និងវិចខ្ចប់ផលិតផលកសិកម្ម អោយទៅជាផលិតផលកសិឧស្សាហកម្ម ព្រមទាំងស្វែងរកទីផ្សារលក់ផលិតផល និងអន្តរាគមន៍ទៅលើតំលៃទីផ្សារ ដើម្បីជួយដល់កសិករ ។
- រាជរដ្ឋាភិបាលកម្ពុជាគួរដាក់បញ្ចូលបញ្ហាចំណាកស្រុក នៅក្នុងគោលនយោបាយអភិវឌ្ឍន៍សាធារណៈដោយផ្អែកលើគោលការណ៍នៃការគ្រប់គ្រងចំណាកស្រុក ដែលចេញដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជា ។
- រាជរដ្ឋាភិបាលកម្ពុជាគួរពង្រឹងការអនុវត្តន៍ច្បាប់អន្តោរប្រវេសន៍កម្ពុជាអោយមានប្រសិទ្ធិភាព និងធ្វើការចុះបញ្ជីពលករបរទេស និងពង្រឹងការធ្វើអធិការកិច្ចចំពោះពលករបរទេស ដែលកំពុងធ្វើការងារនៅក្នុងប្រទេសកម្ពុជា ដើម្បីធានាថាពលករបរទេសទាំងនោះ ទទួលបាននូវការពារ និងគាំពារពីច្បាប់នៃប្រទេសកម្ពុជា ។

## ឯកសារយោង:


(CHRAC), C. H. (2014, June 12). Statement on Cambodian Migrant Workers Deported. Phnom Penh, Cambodia.

(MoLVT), M. o. (2014, July 01). Consultative Meeting on Impact on Cambodian Mass Deportation . Building S at Ministry of Interior , Phnom Penh, Cambodia.

(RFA), R. F. (2014, June 16). RFA's Listener Forum. *Impact on Cambodian Migrant Workers Mass Deportation by Thai Junta* . Phnom Penh, Cambodia: Radio Free Asia (RFA).

*2014 Thai Coup detat* . (n.d.). Retrieved July 29, 2014, from Wikipedia: http://www.en.m.wikipedia.org

Xinhua. (2014, June 22). *Global Times*. Retrieved June 23, 2014, from Thai junta arrests 13 Cambodian workers fro trial as 232,000 cross border back to Cambodia: http://www.globaltimes.cn/content

Bosavy. (n.d.). *VoD Hot News*. Retrieved June 15, 2014, from http://vodhotnews.com/22186

Bosavy. (n.d.). *VoD Hot News*. Retrieved June 15, 2014, from http://vodhotnews.com/22179

Cambodia, C. (2014, June 18). CARAM Press Release on Establishment of Migrant Workers Foundation

Phnom Penh, Cambodia.

CEN. (2014, June). *CEN*. Retrieved June 2014, from http://www.cen.com.kh/local/

Kear, B. R. (2014). Challenges and Impoact of Cambodian Migrant Workers after being Deported by Thai

junta. *Phnom Penh Post*.

Prek, P. (n.d.). *Koh Sontepheap News*. Retrieved June 15, 2014, from

http://kohsantepheapdaily.com.kh/article/98234.html#.U50FhvG_w6Q.facebook

Sophon. (n.d.). *CEN News*. Retrieved June 15, 2014, from www.cen.com.kh